00802939

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 04 / 2012
ម៉ោង (Time/Heure) : 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
E1/56

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បត្តិ៍ ទី ២៩ ខែ មីនា ឆ្នាំ ២០១២

## **សវនាការលើអង្គសេចក្តី - ថ្ងៃទី ៤៤**

រៀបចំដោយ: សែ កុលវុឌ្ឍី និង **Roger PHILLIPS**

| <u>កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ</u> |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ដាវ អានសាន, លោក Roger PHILLIPS. |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក William SMITH, លោក Mr. Dale Lysak, លោក ប៉ាក ចន្ទលីណូ |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN ,លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោកស្រី Lyma NGUYEN, លោកស្រី ជេត វណ្ណលី, លោក វ៉ែន ពៅ, លោក គីម ម៉េងឃី, លោក ឡោ ជុនធី, លោក Barnabé NEKUIE, លោក ហុង គីមសួន |
| សាក្សី៖ កាំង ហ្កេកអ៊ាវ ហៅ ឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Philippe GOUT |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃព្រហស្បត្តិ៍ ទី២៩ ខែ មីនា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.០០ (៧ម៉ោង) |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ (២០នាទី) |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ (១ម៉ោង២០នាទី) |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ (២០នាទី) |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការបន្តតាំងសំណួរទៅសាក្សី កាំង ហ្កេកអ៊ាវហៅឌុច | សហព្រះរាជអាជ្ញា | ៩.០០ | ១៦.០០ |
| ការពិភាក្សាអំពីការបញ្ជាក់យថាភាពនៃចំណារ និងការជំទាស់ចំពោះការតាំងសំណួរ | មេធាវីការពារឲ្យ អៀងសារី<br>មេធាវីការពារឲ្យ នួន ជា<br>អង្គជំនុំជម្រះ | ១១.១០ | ១១.៤៨ |
| សំណើសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ ដោយបន្តតាមដានដំណើរការនីតិវិធីពីបន្ទប់រង់ចាំ | មេធាវីការពារឲ្យ អៀង សារី<br>មេធាវីការពារឲ្យ នួន ជា | ១០.៣០<br>១២.១០ | ១០.៣០<br>១២.១០ |
| សំណើសុំបន្ថែមពេលវេលាសម្រាបតាំងសំណួរទៅសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច | សហព្រះរាជអាជ្ញា | ១៤.៣៥ | ១៥.០០ |

00802941



| | | | |
|---|---|---|---|
| ការជំទាស់ចំពោះការតាំងសំណួរទៅលើឯកសារដែលសាក្សីមិនស្គាល់ | មេធាវីការពារឱ្យ ខៀវ សំផន អង្គជំនុំជម្រះ | ១៥.៣០ | ១៥.៣៥ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការបន្តតាំងសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច**

សហព្រះរាជអាជ្ញាបានបន្តតាំងសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច។

**ការពិភាក្សាអំពីការបញ្ជាក់យថាភាពនៃចំណារ និងការជំទាស់ទៅលើការតាំងសំណួរទៅសាក្សី**

មេធាវីការពារឱ្យ អៀង សារី បានជំទាស់ទៅនឹងការបង្ហាញយថាភាពនៃចំណារដែលមាននៅលើឯកសារដោយសាក្សី នៅពេលដែលសហព្រះរាជអាជ្ញាបានយកឯកសារមកសួរដេញដោល។ មេធាវីការពារឱ្យ នួន ជា បានជំទាស់ទៅនឹងការតាំងសំណួររបស់សហព្រះរាជអាជ្ញាក្នុងការដឹកមុខឱ្យសាក្សីឆ្លើយទៅនឹងសំណួរ។ អង្គជំនុំជម្រះបានសួរទៅសាក្សីបញ្ជាក់អំពីចំណារដែលមាននៅលើឯកសារដែលបានសួរដោយសហព្រះរាជអាជ្ញា។

**សំណើសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ ដោយសុំចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំនេះ។

**សំណើសុំពេលវេលាបន្ថែមក្នុងការតាំងសំណួរទៅសាក្សី**

សហព្រះរាជអាជ្ញាបានស្នើសុំពេលវេលាបន្ថែម១ម៉ោង និង៣០នាទី ដើម្បីបញ្ចប់ការតាំងសំណួរទៅសាក្សី។ មេធាវីការពារឱ្យ អៀង សារី និងខៀវ សំផន បានជំទាស់ចំពោះសំណើសុំនេះ ប៉ុន្តែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចែករំលែកពេលវេលាមួយម៉ោងទៅឱ្យសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះ បដិសេធចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញា ប៉ុន្តែទទួលយកនូវការចែករំលែកពេលវេលា១ម៉ោងពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**ការជំទាស់ចំពោះការតាំងសំណួរទៅលើឯកសារដែលសាក្សីមិនស្គាល់**

មេធាវីការពារឱ្យ ខៀវ សំផន បានជំទាស់ចំពោះការតាំងសំណួរដោយដកស្រង់កថាខណ្ឌណាមួយពីឯកសារដែលសាក្សីមិនបានស្គាល់។ អង្គជំនុំជម្រះ បានរំលឹកអំពីសេចក្តីសម្រេចរបស់ខ្លួនចំពោះនីតិ

វិធីនៃការបង្ហាញឯកសារចំពោះមុខសាក្សី។

**ការពិភាក្សាអំពីនីតិវិធីនៃការយកឯកសារមកដេញដោល**

មេធាវីការពារឱ្យ ខៀវ សំផន បានស្នើសុំ ឱ្យសាក្សីដំបូង រំលឹកអំពីឯកសារដែលយកមកបង្ហាញ បន្ទាប់ពីធ្វើការដេញដោលទៅលើឯកសារនោះ។ អង្គជំនុំជម្រះបានរំលឹកអំពីសេចក្តីសម្រេចរបស់ខ្លួន អំពីនីតិវិធីនៃការយកឯកសារមកធ្វើការដេញដោល ក្នុងករណីដែលសាក្សីមិនស្គាល់ឯកសារនោះ គឺ ឯកសារត្រូវដកចេញពីសាក្សី ប៉ុន្តែភាគីអាចសួរសំណួរទាក់ទងនឹងឯកសារនោះបាន។ អង្គជំនុំជម្រះ បានគូសបញ្ជាក់ថា បញ្ហានៃការសួរសំណួរនេះមិនមានលក្ខណៈធ្ងន់ធ្ងរនោះទេ ភាគីអាចប្រើប្រាស់ វិធីផ្សេងៗគ្នាក្នុងការសួរសំណួរទៅសាក្សី។ គ្រប់ភាគីអាចទទួលបានអត្ថប្រយោជន៍ពីវិធីនៃការសួរ សំណួរទាំងនេះ។ សហព្រះរាជអាជ្ញាបានរំលឹកទៅសាក្សីអំពីការចងចាំចំពោះឯកសារជាមុន មុន ពេលសួរសំណួរអំពីឯកសារនោះទៅសាក្សី។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃកិច្ចផ្ទៃក្នុង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/763 | D248/ 3.3 | 00079279-00079282 00275217-00275220 00623528-00623531 | សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុំម្មុយ នីស្តកម្ពុជា Guidance of Central Committe of the CPK Guidance of Central Committe of the CPK | P | | | |
| E3/740 | D108/ 50/1.7 | 00082731-00082731 00305412-00305412 00583932-00583932 | ឧបសម្ព័ន្ធ ៧៖ សេចក្តីណែនាំនៃការប្រើពាក្យអង្គការ និង ពាក្យបក្ស Annex 7: Introduces guidelines on the use of words 'Angkar and Party' issued by Committee 870 on 11 July 1977 and copied to all divisions, regiments and offices throughout Democratic Kampuchea Annex 7: Introduces guidelines on the use of words 'Angkar and Party' issued by Committee 870 on 11 July 1977 and copied to all divisions, regiments and offices throughout Democratic Kampuchea | P | | | |
| E3/1173 | D366/ 7.1.47 5 | 00072484-00072485 00525781-00525782 | មតិណែនាំរបស់ ៨៧០លេខ ២០-៧៦ ស្តីអំពីការទម្លាក់គ្រាប់បែក របស់ចក្រពត្តិអាមេរិកលើក្រុងសៀមរាបថ្ងៃ ទី ២៥ កុម្ភៈ ៧៦ CPK Document entitled "Advice of 870 no 02-76 about bomb drop of American imperialist into Siem Reap province on 25/2/76" | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/183 | D232/ 8.3 | 00019108- 00019124 00183393- 00183406 00292868- 00292884 | [លិខិតបញ្ជាក់ការជំនួសឯកសារ] ឯកសារកម្ពុជាប្រជាធិបតេយ្យ "ការប្រជុំអចិន្ត្រៃយ៍ 09-10-75" [Surrogate Sheet] DK Document entitled "Minutes of the meeting 09 October 1975" [Feuille remplacée] Le document du KD intitulé "Compte-rendu de réunion du 09 Octobre 1975" | P | | | |
| E3/220 | 13.16 | 00000827- 00000828 00182706- 00182707 00323891- 00323891 | កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ថ្ងៃទី ៧ ឧសភា ១៩៧៦ [Corrected 1] Minutes of permanent committee meeting on 7/5/76 Minutes of permanent committee meeting on 7/5/76 | P | | | |
| E3/394 | D228 | 00398220- 00398227 00398228- 00398235 00398236- 00398243 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះ ថ្ងៃទី ២២-១០-២០០៩ Written Record of Interview of Duch by CIJ on 22-10-2009 Procès verbal d'interrogatoire de Duch par CJI le 22-10-2009 | P | | | |
| E3/1546 | D43/I V- Annex 26 | 00173049- 00173056 00753705- 00753710, 00224630- 00224630 00757862- 00757868, 00271450- 00271451 | ឧបសម្ព័ន្ធ២៦: 319bbkkh សម្រង់ចម្លើយសារភាពរបស់ ម៉ុក សំអុល ហៅ ហុង [Partial T.] Annex 26: Excerpt of Confession of Mok Sam-ol alias Hong [Partial T.] Annexe 26: Aveux de MOK Sam Ol alias HONG à S-21 (annotations des extraits de couleur) | P | | | |
| E3/357 | D120 | 00242917- 00242927 00242928- 00242938 00242939- 00242948 | កំណត់ហេតុនៃការសួចម្លើយឌុច ថ្ងៃទី ២៧ វិច្ឆិកា ឆ្នាំ២០០៨ Written Record of Interview of Duch by CIJ on 27-11-2008 Procès verbal d'interrogatoire de Duch par CJI le 27-11-2008 | P | | | |
| E3/963 | D108/ 26.28 2 | 00086716- 00086717 00181772- 00181774 | ឈ្មោះមនុស្សនៅ ក្រសួងការបរទេស ដែលជាប់ចម្លើយខ្មាំង Annex 282: S-21 Prisoner List containing names of implicated persons from the Ministry of Foreign Affairs | P | | | |
| E3/1547 | D43/I V- Annex 41 | 00174100- 00174107 00771346- 00771348 00289865- 00289866 | ឧបសម្ព័ន្ធ ៤១៖ 412bbkkh សម្រង់ចម្លើយសារភាពរបស់ មាត ទូច ហៅ កែម [Partial T.] Annex 41: 412bbkkh Colour copy Excerpt of Confession of Meak Touch alias Kem Annex 41: 412bbkkh Colour copy Excerpt of Confession of Meak Touch alias Kem | P | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| E3/1548 | D43/IV-Annex 47 | 00174132-00174133 00221776-00221776, 00767463-00767463 00766916-00766917, 00289868-00289868 | ឧបសម្ព័ន្ធ ៤៧៖ 440bbkkh សម្រង់ចម្លើយសារភាពរបស់ សាន់ ប៉ូ Annex 47: 451bbkkh Colour copy Excerpt of Confession of San Pau Annexe 47: Aveux de SAN Pau à S-21 | P | | | | |
| E3/1549 | D43/IV-Annex 58 | 00174392-00174434 00224127-00224127, 00769683-00769715 00235669-00235669 | ឧបសម្ព័ន្ធ ៥៨៖ 555bbkkh សម្រង់ចម្លើយសារភាពរបស់ អេង ម៉េងហ៊ាង ហៅ ឆុន Annex 58: 555bbkkh Colour copy Excerpt of Confession of Eng Meng Heang alias Chhon Annexe 58: 555bbkkh L'extrait en copie couleur de la confession de Eng Meng Heang alias Chhon | P | | | | |
| E3/1550 | 5.30 | 00008921-00009001, 00006658-00006711, 00003117-00003122 00759691-00759696, 00182805-00182808, 00249844-00249845 00296021-00296021, 00766791-00766793, 00766901-00766910, 00766888-00766891 | ចម្លើយសារភាពរបស់ ហ៊ូ នឹម ហៅ ភាស់ S-21 Confession of HU Nim alias Phoas, Minister of Propaganda [Partial T.] Confession of Hou Nim alias Phoas | P | | | | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិ និងបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទ អៀង សារី (ម៉ោង ១០.៣០) និង នួន ជា (ម៉ោង ១២.១០) ទៅបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរ មានភ្ជាប់មកជាមួយនិងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំង នាំសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងនាំគាត់មកបន្ទប់សវនាការ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង០៩ ព្រឹក នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២។

| <u>កាលបរិច្ឆេទបន្តសវនាការៈ</u> |
|---|
| សវនាការនឹងបន្តនៅថ្ងៃចន្ទ ទី០២ ខែមេសា ឆ្នាំ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលឧត្តម** Roger PHILLIPS